MEDIA STATEMENT

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

## សម្រាប់ទិវាអន្តរជាតិប្រឆាំងការស្អប់ខ្ពើមអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ

## ថ្ងៃអាទិត្យ ទី១៧ ខែឧសភា ឆ្នាំ២០១៥

## ត្រូវបានរើសអើង និងធ្វើឲ្យងាយរងគ្រោះ៖ យុវជនដែលស្រឡាញ់ភេទដូចគ្នា និងមនុស្សភេទពីរ ត្រូវការឲ្យមានការទទួលស្គាល់ និងកិច្ចការពារសិទ្ធិរបស់ពួកគេ

១៣ ឧសភា ២០១៥ - ថ្លែងមុន ទិវាអន្តរជាតិប្រឆាំងការស្អប់ខ្ពើមអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ ក្រុមអង្គការសហប្រជាជាតិ និងជំនាញការសិទ្ធិមនុស្សអន្តរជាតិ* អំពាវនាវឲ្យមានការបញ្ចប់ការរើសអើង និងអំពើហិង្សាលើយុវជន និងកុមារដែលជាមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និងមនុស្សភេទពីរ។

គណៈកម្មាធិការ អ.ស.ប ស្តីពីសិទ្ធិកុមារ ក្រុមជំនាញការសិទ្ធិមនុស្សរបស់ អ.ស.ប គណៈកម្មការអន្តរអាមេរិកកាំងទទួលបន្ទុកសិទ្ធិមនុស្ស អ្នករាយការណ៍ពិសេសស្តីពីអ្នកការពារសិទ្ធិមនុស្សនៃគណៈកម្មការអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន ព្រមទាំងស្នងការទទួលបន្ទុកសិទ្ធិមនុស្ស របស់ក្រុមប្រឹក្សាអឺរ៉ុប ជំរុញឲ្យរដ្ឋាភិបាលនៅទូទាំងពិភពលោក ការពារយុវជន និងកុមារទាំងនេះ ឲ្យចាកផុតពីអំពើហិង្សា និងការរើសអើង ហើយបញ្ចូលទស្សនៈរបស់ពួកគេលើគោលនយោបាយ និងច្បាប់នានាដែលប៉ះពាល់ដល់សិទ្ធិរបស់ពួកគេ។

"នៅជុំវិញពិភពលោក កុមារ និងយុវជន ដែលជាមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុសស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទទាំងពីរ មនុស្សប្តូរភេទ (LGBT) ឬមនុស្សភេទពីរ ឬបានឃើញដូចអ្វីដែលបានលើកឡើង នៅតែប្រឈមនឹងការមាក់ងាយ ការរើសអើង និងអំពើហិង្សាដោយសារតែទំនោរផ្លូវភេទដែលបានសន្មត ឬទំនោរផ្លូវភេទជាក់ស្តែង និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ ឬដោយសារតែរូបរាងកាយរបស់ពួកគេខុសពីលក្ខណៈពិតប្រាកដជាមនុស្សស្រី ឬមនុស្សប្រុស។

អំពើហិង្សា និងការរើសអើងលើកុមារ និងយុវវ័យ ដែលជាអ្នកស្រលាញ់ភេទដូចគ្នា (LGBT) និងមនុស្សភេទពីរ កើតមាននៅតាមផ្ទះ នៅតាមសាលារៀន និងស្ថាប័នផ្សេងៗ។ យុវជនដែលស្រឡាញ់ភេទដូចគ្នា ជាញឹកញយណាស់ ប្រឈមនឹងការបដិសេធពីក្រុមគ្រួសារ និងសហគមន៍ដែលមិនទទួលស្គាល់ទំនោរផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។ ប្រការនេះអាចធ្វើឲ្យមានអត្រាខ្ពស់នៃការបាត់បង់

ផ្ទះសម្បែង ការផាត់ចេញពីសង្គម និងភាពក្រីក្រ។ កុមារដែលស្រឡាញ់ភេទដូចគ្នា ជាញឹកញយ ទទួលរងការសម្លុតធ្វើបាបពីសំណាក់មិត្តរួមថ្នាក់ និង លោកគ្រូអ្នកគ្រូ ដែលធ្វើឲ្យសិស្សមួយចំនួនបោះបង់ចោលការសិក្សា។ ពួកគេអាចត្រូវបានបដិសេធមិនទទួលចុះឈ្មោះចូលរៀន ឬបណ្តេញចេញពីសាលារៀនក៏សឹងមាន ដោយឈរលើហេតុផលទំនោរផ្លូវភេទជាក់ស្តែង ឬដែលបានសន្មត ឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេ ។

ការមាក់ងាយ និងការរើសអើង ដែលកុមារ និងមនុស្សពេលវ័យស្រឡាញ់ភេទដូចគ្នា កំពុងប្រឈមមានផលប៉ះពាល់អវិជ្ជមានដល់ តម្លៃផ្ទាល់ខ្លួនរបស់ពួកគេ និងធ្វើឲ្យមានអត្រាខ្ពស់នៃជំងឺធ្លាក់ទឹកចិត្ត និងការធ្វើអត្តឃាត ច្រើនជាងមិត្តភ័ក្តិរបស់គេ។ ឥរិយាបថដែលមានលក្ខណៈរើសអើងរបស់អ្នកប្រកបវិជ្ជាជីវៈផ្នែកសុខភាព និងការរឹតត្បិតលើការទទួលបានព័ត៌មាន ក៏បង្កើតជាឧបសគ្គផងដែរសម្រាប់កុមារ និងយុវជនដែលជាមនុស្សស្រឡាញ់ភេទដូចគ្នា និងមនុស្សមានភេទពីរ ក្នុងការទទួលបានសេវាសុខភាពសមស្រប និងសុវត្ថិភាព។

ក្នុងប្រទេសមួយចំនួន យុវវ័យដែលជាមនុស្សស្រលាញ់ភេទដូចគ្នា ទទួលរងគ្រោះថ្នាក់ពីអ្វីដែលគេហៅថាជា "វិធីព្យាបាល" ក្នុងគោលបំណងដើម្បី "កែប្រែ" ទំនោរផ្លូវភេទ ឬអត្តសញ្ញាណរបស់ខ្លួន។ វិធីព្យាបាលបែបនេះ ធ្វើឡើងមិនត្រឹមត្រូវតាមក្រមសីលធម៌ មិនមានលក្ខណៈវិទ្យាសាស្ត្រ និងមិនមានប្រសិទ្ធភាពឡើយ ហើយអាចមានន័យស្មើនឹងការធ្វើទារុណកម្ម។ យុវជនប្តូរភេទ ក៏ខ្វះលទ្ធភាពផងដែរក្នុងការឲ្យគេទទួលស្គាល់អត្តសញ្ញាណយេនឌ័ររបស់ពួកគេ និងត្រូវឆ្លងកាត់នីតិវិធីដែលមានលក្ខណៈរំលោភបំពាន ដូចជាការក្រៀវ ឬការព្យាបាលដោយបង្ខំ។

លើសពីនេះទៅទៀត កុមារ និងយុវជនមានភេទពីរ អាចនឹងទទួលរងនូវការវះកាត់ និងវិធីព្យាបាលដែលមិនចាំបាច់ និងមិនអាចត្រឡប់ទៅរករូបរាងដើមវិញបាន ដោយពុំមានការយល់ព្រមដោយផ្ទាល់ និងទទួលបានព័ត៌មានគ្រប់គ្រាន់ជាមុន ពីសាមីខ្លួន។ ការអន្តរាគមន៍ទាំងនេះអាចបណ្តាលឲ្យទទួលរងការឈឺចាប់ផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងររយៈពេលវែង ដែលប៉ះពាល់ដល់សិទ្ធិទទួលបានបូរណភាពផ្លូវកាយ សេវាសុខភាព ឯកជនភាព និងស្វ័យភាពរបស់កុមារ និងអាចបង្កើតបានជាការធ្វើទារុណកម្ម ឬការធ្វើបាប។ រដ្ឋទាំងឡាយគួរតែហាមឃាត់អន្តរាគមន៍បែបនេះ។

ច្បាប់ដែលដាក់ជាបទព្រហ្មទណ្ឌដល់បុគ្គលទាំងឡាយ ទោះដោយផ្ទាល់ ឬដោយប្រយោលក្តី ដោយឈរលើហេតុផល ទំនោរផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេ កាន់តែបន្ថែមឲ្យមានអំពើហិង្សា និងការរើសអើងថែមទៀត។ នេះរាប់ទាំង ច្បាប់ទាំងឡាយ "ដែលមានលក្ខណៈឃោសនា ប្រឆាំងនឹងមនុស្សប្រុសស្រឡាញ់ភេទដូចគ្នា" ដែលរិតត្បិតដោយបំពាននូវសិទ្ធិសេរីភាពសម្តែងមតិ និងការជួបប្រជុំ ហើយគំរាមកំហែង ការងាររបស់អង្គការអ្នកស្រលាញ់ភេទដូចគ្នា ព្រមទាំងអ្នកការពារសិទ្ធិមនុស្ស។ បើទោះបីមានការអះអាងថា ច្បាប់ទាំងនេះការពារកុមារក៏ដោយ ប៉ុន្តែ ជាទូទៅ លទ្ធផលគឺផ្ទុយយ៉ាងជាក់ច្បាស់៖ ច្បាប់ទាំងនោះបង្កឲ្យមានអំពើហិង្សាលើកុមារ និងសកម្មជនវ័យក្មេងដែលហ៊ានសម្តែងមតិប្រឆាំងនឹងការ

រំលោភបំពាន។ ច្បាប់ដែលមានលក្ខណៈរើសអើងទាំងនេះ និងច្បាប់ដែលមានលក្ខណៈរើសអើងផ្សេងទៀត គឺផ្ទុយនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងគួរតែលុបចោល។

រដ្ឋទាំងឡាយត្រូវតែធ្វើសកម្មភាពដើម្បីការពារកុមារ និងមនុស្សពេញវ័យទាំងអស់ឲ្យចាកផុតពីអំពើហិង្សា និងធានាថា ប្រព័ន្ធការពារ និងគាំទ្រកុមារប្រកបដោយប្រសិទ្ធិភាព មានរួចជាស្រេច ដែលរួមមានជម្រក និងយន្តការសុវត្ថិភាពផ្សេងទៀតសម្រាប់អ្នកទាំងឡាយណាដែលត្រូវការកិច្ចការពារ។

ឥរិយាបទសង្គមដែលប្រឆាំងនឹងមនុស្សស្រឡាញ់ភេទដូចគ្នា និង មនុស្សភេទពីរ មិនគួរប្រើជាយុត្តិកម្មដើម្បីពង្រឹងច្បាប់ និង គោលនយោបាយដែលមានលក្ខណៈរើសអើង ធ្វើឲ្យការប្រព្រឹត្តិដោយរើសអើងកើតមានមិនចេះឈប់ឈរ ឬខកខានមិនបានស៊ើបអង្កេត និងផ្តន្ទាទោសអ្នកទាំងឡាយណាដែលទទួលខុសត្រូវចំពោះអំពើហិង្សាលើកុមារ និងយុវជនដែលជាមនុស្សស្រលាញ់ភេទដូចគ្នា និងមនុស្សភេទពីរឡើយ។ រដ្ឋទាំងឡាយត្រូវតែធ្វើសកម្មភាពដើម្បីជម្នះឲ្យបាននូវបុរេវិនិច្ឆ័យ និងផ្ទត់គំនិតបែបចាស់គំរឹល តាមរយៈគំនិតផ្តួចផ្តើមប្រឆាំងនឹងការរើសអើងនៅតាមសាលារៀន និងយុទ្ធនាការអប់រំជាសាធារណៈនានា។ រដ្ឋទាំងនោះគួរតែដោះស្រាយផងដែរនូវការរើសអើងជាលក្ខណៈអន្តរវិស័យ និងអំពើហិង្សាលើយុវជនដែលជាមនុស្សស្រលាញ់ភេទដូចគ្នា និងមនុស្សមានភេទពីរ ដោយឈរលើហេតុផលពូជសាសន៍ និងជាតិពិន្ទុ។

សុខភាព និងសុខុមាលភាពរបស់កុមារ និងមនុស្សពេញវ័យទាំងអស់ ត្រូវតែទទួលបានការការពារ រាប់ទាំងតាមរយៈ ការធានាលទ្ធភាពទទួលបានសេវាសុខាភិបាលដោយគ្មានការរើសអើង និងអប់រំផ្លូវភេទដ៏ទូលំទូលាយ និងដោយការពារសិទ្ធិកុមារ និងមនុស្សពេញវ័យទាំងអស់ ចំពោះអត្តសញ្ញាណ ស្វ័យភាព និងបូរណភាពផ្លូវកាយ និងផ្លូវចិត្តរបស់ពួកគេ។

យើងសូមអំពាវនាវដល់រដ្ឋទាំងឡាយ ឲ្យគោរពតាមកាតព្វកិច្ចរបស់ខ្លួន ក្នុងការគោរព ការការពារ និងការបំពេញសិទ្ធិរបស់កុមារ និងមនុស្សពេញវ័យទាំងអស់ ដោយគ្មានការរើសអើង ដើម្បីធានាថា កុមារ និងយុវជនដែលជាមនុស្សស្រីស្រលាញ់ភេទដូចគ្នា មនុស្សប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និងមនុស្សភេទពីរ ត្រូវបានលើកយកមកពិគ្រោះយោបល់ និងអាចចូលរួមក្នុងកិច្ចពិភាក្សាលើគោលនយោបាយ និងច្បាប់នានា ដែលប៉ះពាល់ដល់សិទ្ធិរបស់ពួកគេ។ យើងសូមអំពាវនាវផងដែរ ដល់ស្ថាប័ននានាខាងសិទ្ធិមនុស្ស និងសិទ្ធិកុមារ ឲ្យបំពេញអាណត្តិរបស់ខ្លួន និងចូលរួមក្នុងការការពារអ្នកទាំងនោះ ឲ្យចាកផុតពីអំពើហិង្សា និងការរើសអើង។"

ចប់

**(*) ជំនាញការៈ**

**គណៈកម្មាធិការ អ.ស.ប ស្តីពីសិទ្ធិកុមារ )CRC)៖**

http://www.ohchr.org/EN/HRBodies/CRC/Pages/CRCIndex.aspx

**ជំនាញការឯករាជ្យរបស់ អ.ស.ប៖** លោក ហ្វីលីព អាលស្តុន អ្នករាយការណ៍ពិសេសស្តីពីភាពក្រីក្របំផុត និងសិទ្ធិមនុស្ស លោក ម៉ៃណា គីអៃ (Mr. Maina Kiai) អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម លោក ដេវិដ កៃយេ (Mr. David Kaye) អ្នករាយការណ៍ពិសេសស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងសម្តែងមតិ និងយោបល់ លោក ដៃនូស ភូរ៉ាស (Mr. Dainius Pūras) អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជនគ្រប់រូបក្នុងការទទួលបានបទដ្ឋានខ្ពស់បំផុតខាងសុខភាពផ្លូវកាយ និងផ្លូវចិត្ត លោក មីសែល ហ្វ័រសត៍ (Mr. Michel Forst) អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស លោក វ៉ាន ម៉េងដេរ (Mr. Juan Méndez) អ្នករាយការណ៍ពិសេសស្តីពីទារុណ និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។

**តំណាងពិសេសរបស់អគ្គលេខាធិការ អ.ស.ប ស្តីពីអំពើហិង្សាប្រឆាំងនឹងកុមារ** លោកស្រី ម៉ារតា សានតូស ប៉ៃអ៊ី (Ms. Marta Santos Pais)៖ http://srsg.violenceagainstchildren.org

**គណៈកម្មការអន្តរអាមេរិកកាំងទទួលបន្ទុកសិទ្ធិមនុស្ស )IACHR):** www.iachr.org

**គណៈកម្មការអាហ្វ្រិកទទួលបន្ទុកសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន (ACHPR)៖** លោកស្រី រ៉ែន អាឡាភីនី-ហ្គានស៊ូ (Ms. Reine Alapini-Gansou) អ្នករាយការណ៍ពិសេសស្តីពីអ្នកការពារសិទ្ធិមនុស្សនៅអាហ្វ្រិក-http://www.achpr.org/

**ក្រុមប្រឹក្សាអឺរ៉ុប៖** អិម នីលស៍ មូអ៊ីហ្សនីគស៍ (M. Nils Muižnieks) ស្នងការទទួលបន្ទុកសិទ្ធិមនុស្ស-http://www.coe.int/en/web/commissioner/home

សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមទាក់ទងមក៖

ជំនាញការ អ.ស.ប និងគណៈកម្មាធិការសិទ្ធិកុមារ (CRC)៖ លោកស្រី ដូលូរ៉េស អាំហ្វង់តេ-កានីបាណូ (Ms. Dolores Infante-Cañibano) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៧៦៨/ អ៊ីមែល dinfante@ohchr.org) លោក សាបៀរ សៃលាយ៉ា (Xabier Celaya) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣/ អ៊ីមែល xcelaya@ohchr.org) ឬ លោកស្រី អេលីហ្សាបេត ត្រូស្សេល្ល (Ms. Elizabeth Throssell) (+៤១ ២២ ៩១៧ ៩៤៦៦ / អ៊ីមែល ethrossell@ohchr.org)

គណៈកម្មការអន្តរអាមេរិកកាំងទទួលបន្ទុកសិទ្ធិមនុស្ស (IACHR)៖ លោកស្រី ម៉ារីយ៉ា អ៊ីសាបែល រីវ៉ឺរ៉ូ (Ms. Isabel Rivero) តាមរយៈទូរស័ព្ទលេខ (+២០២ ៣៧០ ៩០០១ /MRivero@oas.org)

គណៈកម្មការអាហ្វ្រិកទទួលបន្ទុកសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន (ACHPR)៖ rsddh.achpr@gmail.com / au-banjul@africa-union.org

ក្រុមប្រឹក្សាអឺរ៉ុប ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស៖ លោក វ៉ាហាគ មូរ៉ាឌីយ៉ាន់ (Mr. Vahag Muradyan) តាមរយៈទូរស័ព្ទលេខ៖ (+៣៣ (0)៣៩០២១៤០៨៦/ទូរស័ព្ទដៃលេខ៖ +៣៣ (0) ៦ ៦៦ ២៧ ២៤ ៤១ / អ៊ីម៉ែល vahagn.muradyan@coe.int)